Khmer

# ប័ណ្ណសុវត្ថិភាពអំពើហិង្សាតាមផ្ទះ

សូមទូរស័ព្ទ ច្រកទ្វារសម្រាប់អំពើហិង្សាតាមផ្ទះ
និងអំពើហិង្សាក្នុងគ្រួសារសម្រាប់ជនជាតិដើម

**1800 800 098**
(ទូរស័ព្ទឥតគិតថ្លៃ២៤ម៉ោង)

## តើមានសេវាណាផ្សេងទៀតដែលអាចជួយខ្ញុំ?

**ទីកន្លែង Yarrow (1800 817 421)** អាច៖
- ផ្ដល់ជូនការពិគ្រោះយោបល់២៤ម៉ោងឥតគិតថ្លៃ ហើយរក្សាការសម្ងាត់ និងការថែទាំផ្នែកពេទ្យសម្រាប់ការធ្វើបាបខាងផ្លូវភេទ ក្នុងពេលថ្មីៗ។

**គណៈកម្មការសេវាផ្នែកច្បាប់ (1300 366 424)** អាច៖
- ផ្ដល់ជូនការពិគ្រោះយោបល់ខាងផ្លូវច្បាប់ឥតគិតថ្លៃ អំពីអំពើហិង្សាតាមផ្ទះ ច្បាប់គ្រួសារ និងជំនួយខាងផ្លូវច្បាប់។

**សេវាផ្ដត់ផ្គង់ជនរងគ្រោះ (8231 5626 ឬ 1800 182 368 - ការហៅទូរស័ព្ទឥតគិតថ្លៃ នៅតាមទីជនបទ)** អាច៖
- ផ្ដល់យោបល់ និងការបញ្ជូន ហើយក្នុងករណីខ្លះទៀត សេវាពិគ្រោះយោបល់។

**កម្មវិធីការស្នាក់នៅតាមផ្ទះ ការស្នាក់នៅដោយសុវត្ថិភាព** អាចផ្ដល់ជូន៖
- យោបល់ និងការផ្គត់ផ្គង់អំពីសុវត្ថិភាពនៅក្នុងផ្ទះរបស់អ្នក។
- សន្តិសុខសម្រាប់ផ្ទះរបស់អ្នក ដើម្បីជួយធ្វើឲ្យងាយស្រួល។
- វត្ថុសុវត្ថិភាពផ្ទាល់ខ្លួន ដើម្បីជួយអ្នកស្នាក់នៅដោយសុវត្ថិភាព។

## លេខទូរស័ព្ទដ៏មានប្រយោជន៍ផ្សេងទៀត

សេវាផ្នែកច្បាប់សម្រាប់ស្ត្រី - 8221 5553 - 1800 816 349 ( ការហៅទូរស័ព្ទឥតគិតថ្លៃ នៅតាមទីជនបទ )

សេវាអំពើហិង្សាតាមផ្ទះពេញទូទាំងក្នុងរដ្ឋសម្រាប់ក្រុមវប្បធម៌ និងភាសាផ្សេងគ្នា (CALD) - 8346 9417

ខ្សែទូរស័ព្ទជាតិដើម្បីពិគ្រោះយោបល់អំពីការធ្វើបាបខាងផ្លូវភេទ និងអំពីហិង្សាក្នុងគ្រួសារ និងតាមផ្ទះ៖ - 1800 737 732

## កិច្ចការទាំងឡាយដែលត្រូវគិតពិចារណាដើម្បីកែលម្អសុវត្ថិភាពរបស់អ្នក

- សុវត្ថិភាពរបស់អ្នក
  - តើអ្នកត្រូវការដាក់ពាក្យសុំបញ្ជាដើម្បីធ្វើអន្តរាគមន៍ឬទេ ?
  - តើអ្នកបានរៀបចំផែនការសុវត្ថិភាពហើយឬនៅ ?
  - តើកូនរបស់អ្នកបានដឹងពីអ្វីដែលត្រូវធ្វើក្នុងគ្រាអាសន្នឬទេ ?
- សន្តិសុខតាមផ្ទះរបស់អ្នក ប្រសិនបើអ្នកស្នាក់នៅ ឬត្រូវចាកចេញ
  - លេខទូរស័ព្ទសម្ងាត់
  - សន្តិសុខតាមផ្ទះ និងការដាក់គ្រឿងឲ្យភេរវសញ្ញា
  - ផ្លាស់ប្ដូរសោទ្វារផ្ទះ
- សុវត្ថិភាពគ្រឿងបច្ចេកវិទ្យារបស់អ្នក
  - កំណត់ការរៀបចំភាពឯកជន ដើម្បីធ្វើទំនាក់ទំនងជាឯកជន មិនមែនជាសាធារណៈ
  - បង្កើតទម្រង់ថ្មីមួយនៅលើប្រព័ន្ធផ្សព្វផ្សាយសង្គម ដោយមានព័ត៌មានដែលគេពុំអាចសម្គាល់ដឹងប៉ុណ្ណោះ
  - បើក GPS របស់អ្នក ដោយដាក់មុខងារទីតាំង "បិទ" នៅលើទូរស័ព្ទទាន់សម័យរបស់អ្នក
  - និយាយជាមួយកូនរបស់អ្នក អំពីការប្រើប្រាស់គ្រឿងបច្ចេកវិទ្យាដោយសុវត្ថិភាព
- ប្រាប់មិត្តភក្តិដែលជឿទុកចិត្តរបស់អ្នក និងសាច់ញាតិអំពីអំពើហិង្សា ដើម្បីឲ្យបានដឹងពីជំនួយ និងការផ្គត់ផ្គង់អ្វីខ្លះដែលពួកគេអាចផ្ដល់ជូនអ្នក។
- ជូនដំណឹងទៅអ្នកជិតខាង ហើយស្នើសុំជំនួយក្នុងគ្រាមានវិបត្តិ។
- ជូនដំណឹងទៅអ្នកផ្សេងទៀត ( ឧទាហរណ៍ កន្លែងការងារ វេជ្ជបណ្ឌិត មេធាវី) អំពីសារៈសំខាន់នៃការរក្សាភាពឯកជនរបស់អ្នក។
- យកចេញប្រាក់ណាមួយដែលអ្នកមានសិទ្ធិស្របច្បាប់ បន្ទាប់មកបើកគណនីធនាគារថ្មីមួយ ហើយរៀបចំឲ្យគេបើកប្រាក់ចំណូលចូលក្នុងគណនីថ្មីនេះជាបន្ទាន់។
- ប្រាប់សាលារៀន និងអ្នកផ្សេងទៀតដែលថែរក្សាកូនរបស់អ្នក ឈ្មោះអ្នកដែលត្រូវបានអនុញ្ញាតឲ្យធ្វើទំនាក់ទំនងជាមួយពួកគេ។
- ជៀសវាងទីកន្លែងដែលដៃគូរបស់អ្នកអាចរំពឹងទុកថានឹងមើលឃើញអ្នក ឧទាហរណ៍ ហាងលក់ )។
- ត្រូវប្រុងប្រយ័ត្នអំពីនរណាដែលអ្នកនឹងផ្ដល់ជូនអាសយដ្ឋានថ្មី និងលេខទូរស័ព្ទរបស់អ្នក។

the
DOMESTIC VIOLENCE
CRISIS SERVICE *inc.*

SOUTH AUSTRALIA POLICE
KEEPING SA SAFE

Government
of South Australia

## តើអំពើហិង្សាតាមផ្ទះជាអ្វី?

អំពើហិង្សាតាមផ្ទះគឺជាអាកប្បកិរិយារំលោភបំពានដោយដៃគូ ដៃគូពីមុន នរណាម្នាក់ដែលអ្នកមានទំនាក់ទំនងជិតស្និតជាមួយ ឬសមាជិកនៃគ្រួសាររបស់អ្នក រួមមានមនុស្សទូទាំងជំនាន់ដែលបានប្រើដើម្បីគ្រប់គ្រង ឬបន្លាចអ្នក។ ការរំលោភបំពានអាចកើតចេញពីសណ្ឋានខុសៗគ្នានៃទម្រង់បែបបទទាំងឡាយ  រួមទាំងការរំលោភបំពានផ្លូវកាយ ផ្លូវភេទ អារម្មណ៍ ផ្លូវចិត្ត ឬសេដ្ឋកិច្ច។

សូមចាំថា វាមិនមែនជាកំហុសរបស់អ្នកទេដែលថា អ្នកកំពុងត្រូវគេរំលោភបំពាន។ មានជំនួយ។ អ្នកមិនឯកោទេ។ មានជម្រើសទាំងឡាយ។

មានសេវាអំពើហិង្សាក្នុងគ្រួសារដែលគ្រដណ្តប់គ្រប់តំបន់នៃរដ្ឋអូស្ត្រាលីខាងត្បូង ដែលអាចជួយ និងគាំទ្រអ្នកនៅក្នុងវិធីផ្សេងៗ។ ដើម្បីឲ្យគេតភ្ជាប់ទៅសេវាទាំងនេះណាមួយ សូមទូរស័ព្ទសេវាធ្វើការ ២៤ម៉ោងឥតគិតថ្លៃពេញទូទាំងរដ្ឋ លេខ 1800 800 098 នោះពួកគេនឹងផ្តល់ព័ត៌មាន យោបល់ និងការបញ្ជូនទៅកាន់សេវាមួយក្នុងតំបន់ ដែលសមនឹងតម្រូវការជាក់លាក់របស់អ្នក។

ប្រសិនបើអ្នកចង់បានការផ្គត់ផ្គង់ ឬសម្រេចចិត្តដើម្បីចាកចេញពីផ្ទះ
សូមទូរស័ព្ទលេខ 1800 800 098។

### តើគេអាចជួយដោយបែបណា?

នៅក្នុងការភ្ជាប់គ្នាជាមួយសេវាអំពើហិង្សាតាមផ្ទះក្នុងតំបន់របស់អ្នក ពួកគេអាចផ្តល់ជូន:

- ព័ត៌មាន និងការគាំទ្រ។
- ការពិគ្រោះយោបល់ និងការគាំទ្រមតិ។
- ទីកន្លែងស្នាក់នៅសម្រាប់គ្រាបន្ទាន់។
- ជំនួយជាមួយនឹងទីកន្លែងស្នាក់នៅរយៈពេលយូរ។
- ជំនួយផ្នែកហិរញ្ញវត្ថុ។
- ការគាំទ្រ និងព័ត៌មានបទបញ្ជាដើម្បីធ្វើអន្តរាគមន៍។

### ប្រសិនបើខ្ញុំត្រូវការចាកចេញ តើខ្ញុំគួរយកអ្វីខ្លះទៅជាមួយខ្ញុំ?

- ប័ណ្ណ – ATM/គណនីធនាគារ ប័ណ្ណបើកបររថយន្ត មេឌីឃែរ និងព័ត៌មានអំពី Centrelink។
- ឯកសារឯទៀត – សំបុត្រកំណើត សំបុត្រអាពាហ៍ពិពាហ៍ សំបុត្រលះលែងគ្នា លិខិតឆ្លងដែន បញ្ជាតុលាការសម្រាប់គ្រួសារ កិច្ចព្រមព្រៀងជួលទីលំនៅ វិក្កយបត្រសេវាសំខាន់ៗ ការចុះឈ្មោះរថយន្ត។
- ថ្នាំពេទ្យ និងគ្រឿងសំអាង។
- សោផ្ទះ សោឡាន និងសោកន្លែងធ្វើការ។
- ប្រាក់ កាក់សម្រាប់ប្រើប្រាស់ទូរស័ព្ទសាធារណៈ។
- ទូរស័ព្ទចល័ត និងគ្រឿងបញ្ចូលថ្មទូរស័ព្ទ។
- លេខទូរស័ព្ទសម្រាប់ក្រុមគ្រួសារ និងមិត្តភក្តិ។
- សម្លៀកបំពាក់សម្រាប់ផ្លាស់ប្តូរ និងម្ហូបអាហារសំខាន់ៗ

### ចុះចំណែកកូនៗរបស់ខ្ញុំ?

- យកកូនទៅជាមួយអ្នកឲ្យបានឆ្ងាយផុតពីអំពើហិង្សា។
- យកម្សៅទឹកដោះគោ សម្លៀកបំពាក់សម្រាប់ផ្លាស់ប្តូរ ប្រដាប់ក្មេងលេង ឬសៀវភៅដែលក្មេងចូលចិត្ត ឯកសណ្ឋានសាលា សៀវភៅសិក្សា កំណត់ត្រាសុខភាព។

### ចុះចំណែកសត្វចិញ្ចឹមរបស់ខ្ញុំ?

ស្នើសុំមិត្តភក្តិឲ្យគេជួយមើលថែសត្វចិញ្ចឹម ឬទូរស័ព្ទ៖

- សម្ព័ន្ធសុខុមាលភាពសត្វចិញ្ចឹម លេខ 83481300.
- RSPCA លេខ 1300 477 722។

## តើមានសេវាកម្មណាផ្សេងទៀតដែលអាចជួយខ្ញុំ?

### ប៉ូលិសរដ្ឋអូស្ត្រាលីខាងត្បូង (131 444 ឬ 000) អាច៖

- ធានាថាអ្នក និងកូនរបស់អ្នកមានសុវត្ថិភាពរួចផុតពីគ្រោះថ្នាក់ថែមទៀត ហើយជួយសម្រួលដល់ការដឹកជញ្ជូនសម្រាប់អ្នក និងកូនរបស់អ្នក ទៅកន្លែងដែលមានសុវត្ថិភាពមួយនៅក្នុងការគ្រាបន្ទាន់។
- ស៊ើបអង្កេតរឿងរ៉ាវ ហើយអាចដាក់បណ្តឹងពីបទចោទប្រកាន់។
- អាចជួយអ្នកទទួលបានបញ្ជាដើម្បីធ្វើអន្តរាគមន៍មួយ (បញ្ជារបស់តុលាការ ដែលហាមមិនឲ្យមនុស្សម្នាក់ប្រព្រឹត្តការរំខានយាយី គំរាមកំហែង ឬលក្ខណៈហិង្សាមកកាន់អ្នក ហើយអាចបង្ការមនុស្សដែលបានចូលរួមក្នុង ឬរក្សានៅក្នុងផ្ទះ ឬកន្លែងការងាររបស់ អ្នក)។

### Centrelink (13 61 50) អាច៖

- ចាត់ចែងកាតព្វកិច្ចរបស់អ្នក ដើម្បីទទួលបានប្រាក់ផ្គត់ផ្គង់បន្តទៀត។
- ជួយរៀបចំការផ្លាស់ប្តូរ ដើម្បីទទួលបានប្រាក់ផ្គត់ផ្គង់របស់អ្នក។
- អាចផ្តល់ជូនអ្នកនូវជំនួយផ្នែកហិរញ្ញវត្ថុ។

### គ្រួសារ SA 8226 1000

លំនៅដ្ឋាន SA (13 12 99) នៅក្នុងកាលៈទេសៈខ្លះ អាចផ្តល់ជូន៖

- កន្លែងស្នាក់នៅបណ្តោះអាសន្នក្នុងគ្រាមានវិបត្តិ។
- ជួយចេញប្រាក់កក់ធានា និងថ្លៃជួលផ្ទះ ដើម្បីទទួលបានទីលំនៅឯកជន។
- អ្នកជួលទីលំនៅ  Housing SA ជាមួយដំបូន្មានអំពីវិធានការសុវត្ថិភាព និងសន្តិសុខ។
- អ្នកដាក់ពាក្យសុំរបស់ Housing SA ជាមួយការវាយតម្លៃឡើងវិញនៃពាក្យសុំសម្រាប់បញ្ជីរង់ចាំរបស់គេ។